វិទ្យាស្ថានបណ្តុះបណ្តាល
និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ក្រសួងផែនការ

សាកល
វិទ្យាល័យភូមិន្ទភ្នំពេញ

IDRC CRDI

ទីស្តីការគណៈរដ្ឋមន្ត្រី

ឧត្តមក្រុមប្រឹក្សា
សេដ្ឋកិច្ចជាតិ

សង្ខេបសម្រាប់
# គោលនយោបាយ

ឆ្នាំ ២០១២ លេខ ១០

# តួនាទីសំខាន់នៃឥណទានជនបទនៅកម្ពុជា ក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល

*លន់ ពិដេ*[១]

មានការសិក្សាកាន់តែច្រើនបានបង្ហាញថា ទីផ្សារឥណទានជនបទដើរតួនាទីយ៉ាងធំក្នុងអំឡុងពេលមានវិបត្តិ (Udry 1994; Besley 1995)។ តាមទ្រឹស្តី និងក្នុងការអនុវត្តជាក់ស្តែង ប្រជាជននៅជនបទ ប្រើប្រាស់ឥណទានមិនមែនសម្រាប់តែវិនិយោគដើម្បីជីវភាពរស់នៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់ដោះស្រាយវិបត្តិ មានជាអាទិ៍ គ្រោះធម្មជាតិ មរណភាពសមាជិកគ្រួសារ និងការឈឺថ្កាត់ ក៏ដូចជា កង្វះប្រាក់សម្រាប់ដោះស្រាយចំណាយប្រើប្រាស់ដោយសារការធ្លាក់ចុះប្រាក់ចំណូល។

អត្ថបទសង្ខេបនេះ ផ្តល់ព័ត៌មានបន្ថែមដល់អ្នកធ្វើគោលនយោបាយ អំពីតួនាទីសំខាន់នៃឥណទានជនបទនៅកម្ពុជា ក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល។ អត្ថបទនេះពិនិត្យដោយសង្ខេបពីឥណទានជនបទនៅកម្ពុជា ជាពិសេស ក្នុងឆ្នាំ២០០៨ ព្រមទាំងវិភាគពីតម្រូវការឥណទានផ្លូវការ និងក្រៅផ្លូវការ នៃគ្រួសារនៅជនបទ ក្នុងអំឡុងពេលមានវិបត្តិសាកល និងលើកស្នើឡើងនូវជម្រើសគោលនយោបាយមួយចំនួន។

## ទីផ្សារឥណទានជនបទក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល

វិបត្តិចំពោះទីផ្សារឥណទាន អាចពិភាក្សាតាមសេណារីយ៉ូពីរ។ ទី១ វិបត្តិជារឿយៗតែងនាំឲ្យកសិករមិនអាចសងបំណុលបាន ដែលធ្វើឲ្យអ្នកផ្តល់កម្ចីរឹតបន្តឹង ឬបញ្ឈប់ការផ្តល់កម្ចី។ ប៉ុន្តែវិបត្តិប្រហែលមិនប៉ះពាល់ដល់ការផ្គត់ផ្គង់ឥណទានទេ ប្រសិនបើអ្នកផ្តល់កម្ចីធ្វើពិពិធកម្មកម្ចីរបស់ខ្លួន ពោលគឺ ផ្តល់ទៅលើវិស័យផ្សេងៗទៀតដែលមិនប៉ះពាល់ដោយវិបត្តិ។ ទោះយ៉ាងនេះក្តី ចំពោះវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលដែលបានរាលដាលប៉ះពាល់ដល់មនុស្សគ្រប់គ្នាបែបនេះ ឥណទានអាចមានតិច ទោះបីមានការធ្វើពិពិធកម្មកម្ចីក្តី។

តារាង ១៖ កម្ចីនៅជំពាក់របស់ស្ថាប័នមីក្រូឥណទាននៅកម្ពុជា

| កម្ចីនៅជំពាក់ | 2007 | 2008 | 2009 |
|---|---|---|---|
| បរិមាណ | 272.00 | 277.06 | 299.30 |
| ចំនួនអ្នកខ្ចី | 777,481 | 825,238 | 878,559 |

ប្រភព៖ CMA 2008 and CMA 2009

នៅកម្ពុជា ការផ្គត់ផ្គង់ឥណទានជនបទបានកើនឡើង ទោះបីក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលក្តី។ ទិន្នន័យស្តីពីកម្ចីនៅជំពាក់ របស់ស្ថាប័នមីក្រូហិរញ្ញវត្ថុនានា បង្ហាញថាពីឆ្នាំ២០០៨ ដល់ ២០០៩ បរិមាណកម្ចីនៅជំពាក់កើនឡើងប្រហែល ៨% ហើយចំនួនអ្នកខ្ចីប្រាក់កើន ៦,៥% (តារាង ១)។ ប៉ុន្តែក្រោយពេលកើតវិបត្តិ ចំនួនកម្ចីដែលមានហានិភ័យ និងចំនួនកម្ចីច្រើនមុខ បានកើនជាខ្លាំង (CMA 2008, 2009)។ ដើម្បីដោះស្រាយការប៉ះទង្គិចលើប្រាក់ចំណូល គ្រួសារកំពុងជាប់បំណុលស្រាប់នោះ បានស្វែងរកប្រាក់កម្ចីបន្ថែមទៀតពីប្រភពផ្សេងទៀត ដែលនាំឲ្យមានកំណើន ចំនួនកម្ចីច្រើនមុខ និងកម្ចីដែលមានហានិភ័យ *(ibid)*។

ទិន្នន័យទាំងនេះ បង្ហាញមួយភាគថា ទីផ្សារឥណទានជនបទនៅប្រទេសកម្ពុជា ពិតជាបានជួយប្រជាជនក្នុងពេលមានវិបត្តិមែន។ គួរកត់សម្គាល់ដែរថា ការផ្គត់ផ្គង់ឥណទានជាបន្តបន្ទាប់នៅកម្ពុជា ក៏កើតមានឡើង ដោយសាររដ្ឋាភិបាលបានជំរុញការផ្តល់កម្ចីពីធនាគារ ដើម្បីលើកទឹកចិត្តវិនិយោគ និងជួយទ្រទ្រង់កំណើនផងដែរ។

## តម្រូវការឥណទានរបស់គ្រួសារនៅជនបទ ក្នុងពេលមានវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល

គ្រួសារនៅជនបទ ស្វែងរកឥណទានទាំងពីប្រភពផ្លូវការ និងមិនផ្លូវការ។ ប្រភពមិនផ្លូវការ សំដៅលើក្រុមពីរ គឺ ១) សាច់ញាតិ

[១] លោក លន់ ពិដេ ជាអ្នកស្រាវជ្រាវ នៃកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៅវិទ្យាស្ថាន CDRI។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១ ៣៨៤/៨៨១ ៧០១/៨៨១ ៩១៦/៨៨៣ ៦០៣
🖷 (៨៥៥-២៣) ៨៨០ ៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

មិត្តភក្តិ ឬអ្នកជិតខាង និង ២) អ្នកផ្តល់កម្ចីឯកជន។ ជាទូទៅ ក្រុមទី១ តែងមិនគិតការប្រាក់ឡើយ រីឯ ក្រុមទី២ យកការប្រាក់ខ្ពស់។ ប្រភពផ្លូវការ រួមមាន ធនាគារ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និង អង្គការមិនមែនរដ្ឋាភិបាល។

មានភស្តុតាងបញ្ជាក់ថា នៅអំឡុងពេលមានវិបត្តិសាកលក្នុងឆ្នាំ២០០៨ គ្រួសារជាច្រើននៅកម្ពុជាជាប់បំណុលច្រើនជាងមុន។ ដោយប្រឈមមុខនឹងការធ្លាក់ចុះប្រាក់ចំណូល ប្រជាជនបានខ្ចីប្រាក់បន្ថែមទៀតពី ស្ថាប័នមីក្រូហិរញ្ញវត្ថុ អ្នកផ្តល់កម្ចីឯកជន និង បណ្តាញសង្គមនានា (Jalilian *et al.* 2009)។ ការសិក្សាដោយ Theng and Kem (2009) បង្ហាញថា ចំនួនអ្នកខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុ បានកើនឡើងយ៉ាងច្រើន ដល់ទៅ ៥០% ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០០៩។

ចំណែកឯលទ្ធផលនៃការសិក្សាដោយ Lun (ចេញផ្សាយក្នុងពេលខាងមុខ) ស្តីពីតួនាទីនៃឥណទានជនបទ ក្នុងអំឡុងវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល បង្ហាញថា (១) វិបត្តិបានជំរុញគ្រួសារឲ្យខ្ចីបុលកាន់តែច្រើន និង (២) ការធ្លាក់ចុះនៃប្រាក់ចំណូលក្នុងគ្រួសារដែលប្រហែលជាបណ្តាលមកពីវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល ក៏មានទំនាក់ទំនងវិជ្ជមានជាមួយនឹងកំណើននៃការខ្ចីបុលរបស់គ្រួសារដែរ។

អត្ថបទនេះបង្ហាញដែរថា វិបត្តិសាកលជម្រុញឲ្យគ្រួសារខ្ចីប្រាក់ច្រើនជាងមុន ទាំងតាមច្រកផ្លូវការ និងមិនផ្លូវការ ប៉ុន្តែកម្ចីជាលក្ខណៈផ្លូវការឃើញថា មានកំណើនខ្ពស់ជាងកម្ចីមិនផ្លូវការ។ នេះបង្ហាញថា ឥណទានផ្លូវការ ដូចជាកម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុជាដើម មានតួនាទីកាន់តែសំខាន់ខ្លាំងឡើងក្នុងអំឡុងពេលមានវិបត្តិ។ ទិន្នន័យស្តីពីចំនួនកម្ចីដែលផ្តល់ដោយស្ថាប័នមីក្រូហិរញ្ញវត្ថុ ក្នុងអំឡុងពេលនៃវិបត្តិសាកល ដែលមានកម្រិតខ្ពស់ជាងមុនពេលកើតវិបត្តិ ក៏បានបង្ហាញថា ស្ថាប័នមីក្រូហិរញ្ញវត្ថុមានតួនាទីសំខាន់ដែរ។

នៅអំឡុងពេលមានវិបត្តិសាកល គ្រួសារនៅជនបទមិនខ្ចីបុលសម្រាប់ចំណាយលើអាហារទេ ប៉ុន្តែដើម្បីយកទៅវិនិយោគលើកសិដ្ឋាន និងសងបំណុលគេ។ ក្នុងការអនុវត្តជាក់ស្តែង គ្រួសារនីមួយៗត្រូវធានាថា ចំណូលរបស់ខ្លួនអាចដោះស្រាយចំណាយប្រចាំថ្ងៃ និងអាចបែងចែកទុកខ្លះសម្រាប់ធ្វើជាដើមទុនក្នុងការងារកសិកម្ម ដើម្បីបានចំណូលមកផ្គត់ផ្គង់ចំណាយក្នុងគ្រួសារនៅថ្ងៃមុខ។ ម៉្យាងវិញទៀត ពួកគាត់ក៏ត្រូវប្រើចំណូលដែលបានមកមួយភាគសម្រាប់សងបំណុលដែរ។ ឥណទានជួយឲ្យគ្រួសារទប់ទល់នឹងវិបត្តិ ប៉ុន្តែការធ្លាក់ខ្លួនជាប់បំណុលធ្ងន់ធ្ងរពេក ក៏អាចបង្កើនភាពក្រីក្រដែរ។

## ជម្រើសគោលនយោបាយ

លទ្ធផលពីការសិក្សានេះ អាចជួយរួមចំណែកដល់ការធ្វើគោលនយោបាយនៅកម្ពុជា។ ខាងក្រោមនេះ ជាគន្លឹះមួយចំនួនដែលគួរគិតគូរពិចារណា។

- ឥណទានផ្លូវការ មានសារៈសំខាន់សម្រាប់គ្រួសារនៅជនបទក្នុងអំឡុងពេលមានវិបត្តិ ដូច្នេះគួរផ្តោតលើការពង្រីកលទ្ធភាពផ្តល់ឥណទានផ្លូវការឲ្យបានទូលំទូលាយ។
- គួរផ្តល់ឥណទានជាទុន សម្រាប់វិនិយោគក្នុងវិស័យកសិកម្មក្នុងគ្រួសារឲ្យបានច្រើន ព្រោះប្រជាជននៅជនបទភាគច្រើនពឹងផ្អែកខ្លាំងលើវិស័យកសិកម្ម។
- ប្រព័ន្ធធានារ៉ាប់រងសង្គម គួរមានបញ្ចូលកម្មវិធីមីក្រូឥណទានដែលមិនតំរូវឲ្យមានដាក់របស់បញ្ចាំ សម្រាប់អ្នកក្រីក្រ និងក្រុមជនងាយរងគ្រោះ។ កម្ពុជាអនុវត្តកិច្ចការនេះបានល្អ ដូច្នេះត្រូវតែធ្វើបន្ត និងពង្រីកថែមទៀត។
- គួរចៀសវាង កម្មវិធីឧបត្ថម្ភធនលើឥណទាន នៅពេលចង់បង្កើនលទ្ធភាពទទួលបានឥណទាននៅជនបទ។ ជោគជ័យនៃកម្មវិធីឥណទាន គឺអាស្រ័យលើភាពស៊ីសង្វាក់គ្នានៃគ្រឿងលើកទឹកចិត្ត និងនីតិវិធីអនុវត្តដែលរឹងមាំទៅវិញទេ។
- ការពង្រីកប្រភពផ្សេងទៀតដើម្បីទទួលបានឥណទាន អាចជាមធ្យោបាយមួយ ដើម្បីបន្ទាបអត្រាការប្រាក់របស់អ្នកផ្តល់កម្ចីឯកជន។ អ្នកផ្តល់ឥណទានថ្មីៗ ត្រូវដោះស្រាយបញ្ហាខាងផ្នែកព័ត៌មាន (ព័ត៌មានពីអ្នកខ្ចី) ដែលតែងជាកត្តារាំងដល់ការឈានចូលទីផ្សារឥណទាន។